# រឿងទាក់ទិននឹងទណ្ឌកម្មមានជាបន្ត

*ដី ទេវិទ្ធ*

ព្រឹកនេះ សំ មេធ ដែលជាអតីតកងសន្តិសុខយាម "អ្នកទោសសំខាន់" ក្នុងគុកទួលស្លែង (ស-២១) បន្តការផ្តល់សក្ខីកម្មលម្អិតអំពីដំណើរការនៃគុកដែលគ្រប់គ្រងដោយជនជាប់ចោទឈ្មោះ កាំង ហ្គេចអៀវ (ហៅ ឌុច) ។ គាត់ផ្តល់កសិណជាបន្តចំពោះមុខចៅក្រមនិងគ្រូបង្រៀនមកពីតំបន់តាខ្មៅប្រមាណ៨០០នាក់ដែលបានមកទស្សនា ។

ឆ្លើយតបទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាជាតិ សំ មេធ បាននិយាយថាគាត់បានឃើញផ្ទាល់នឹងភ្នែកនូវការប្រើប្រាស់ទារុណកម្មក្នុងអំឡុងពេលបម្រើការងារនៅមន្ទីរស-២១ ។ ឧទាហរណ៍ គាត់បានឃើញគេចាក់ទឹកកកទៅលើខ្លួនអ្នកទោសម្នាក់ក្រោយពេល ត្រូវសម្រាតរហូតសល់តែខោអាវក្នុង ។ បន្ទាប់មក គេបានសួរការយល់ឃើញរបស់គាត់ទៅលើគំនូរពណ៌នាអំពីការដកក្រចកដៃអ្នកទោសម្នាក់គូរដោយ លោក វ៉ាន់ ណាត ដែលធ្លាប់ជាអ្នកទោសនិងជាជាងគំនូរម្នាក់នៅមន្ទីរស-២១ ។ សំ មេធ ឆ្លើយតបថា គាត់មិនដែលបានឃើញហេតុការណ៍បែបនេះផ្ទាល់នឹងភ្នែកទេ តែគាត់បានឃើញស្នាមរបួសខ្លះដែលបង្ហាញថាពិតជាត្រូវគេដកក្រចកមែន ។ មេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីបានបន្តសំណួរនេះដោយសួរបញ្ជាក់ សំ មេធ អំពីវិធីធ្វើទារុណកម្មផ្សេងៗដូចជាការឆក់ប្រដាប់ភេទដោយចរន្តអគ្គិសនី ។ ប៉ុន្តែ សំ មេធ បដិសេធមិនចង់និយាយច្រើន ដោយគ្រាន់តែឆ្លើយថាគាត់បានប្រាប់អ្វីដែលគាត់បានដឹងនិងឃើញដល់សវនាការរួចអស់ហើយ ។

សំ មេធ ថែមទាំងនិយាយថា ឌុច ជួនកាលចូលទៅមើលក្នុងបន្ទប់សួរចម្លើយក្នុងករណី "អ្នកទោសសំខាន់"ខ្លះ ហើយ ឌុច ក៏គាំទ្រពីពាក្យសម្តីនេះដោយបញ្ជាក់ថាគាត់ធ្លាប់ចូល ទៅមើលពេលដែលអ្នកទោសកំពុងត្រូវធ្វើទារុណកម្ម ។ ចំពោះសំណួរទាក់ទងទៅនឹងចរិតលក្ខណៈរបស់អ្នកសួរចម្លើយក្នុងមន្ទីរស-២១ សំ មេធ បានឆ្លើយយ៉ាងខ្លីថា "អ្នកសួរចម្លើយទាំងអស់សុទ្ធតែកាចសាហាវទាំងអស់" ។

## រស់នៅក្នុងការភ័យខ្លាច

សំ មេធ បន្តសក្ខីកម្មដោយបង្ហាញពីការភ័យខ្លាចចំពោះ ឌុច ។ គាត់និយាយថា ថ្វីត្បិត ឌុច មិនដូចជាមនុស្សឃោរឃៅម្នាក់ តែ សំ មេធ "តែងតែខ្លាចគាត់ជានិច្ច" ។ លើសពីនេះ គាត់អះអាងថា គាត់មិនដែលសប្បាយចិត្តនឹងការងារនៅក្នុងមន្ទីរស-២១ទេ តែគាត់ត្រូវបិទបាំងអារម្មណ៍ពិតដែល

ភ័យខ្លាចនឹងត្រូវគេចាប់ខ្លួន ។ ដាក់ស្តែង ក្នុងចំណោមសមាជិកកងហាររបស់គាត់ មានតែគាត់និងបីបួននាក់ទៀតប៉ុណ្ណោះ ដែលគេចផុតពីសេចក្តីស្លាប់ ។

សំ មេធ បានក្លាយទៅជាមុខសញ្ញាជាប់សង្ស័យម្នាក់ពេលដែលបងប្រុសគាត់ឈ្មោះ ម៉េង និងប្រពន្ធគាត់ឈ្មោះ ធឿង ត្រូវបានចាប់ខ្លួនរួចបញ្ជូនទៅមន្ទីរស-២១ ។ ទីបំផុត គាត់ទាំងពីរនាក់សុទ្ធតែត្រូវបានសម្លាប់ ។ តាមសម្តីរបស់ សំ មេធ អ្នកដែលជួយឲ្យគាត់អាចនៅរស់គឺ ហ៊ឹម ហ៊ុយ ។ ហ៊ឹម ហ៊ុយ គឺជាអ្នកប្រាប់ សំ មេធ ថាបងប្រុសរបស់គាត់ត្រូវគេចាប់ខ្លួន ។ សំ មេធ អះអាងថា គាត់ពិបាកនឹងប្រមូលអារម្មណ៍បន្តការងារណាស់ ក្រោយពីទទួលបានដំណឹងនេះ ប៉ុន្តែគាត់អាចរស់រានមានជីវិតដោយសារតែការណែនាំរបស់ ហ៊ឹម ហ៊ុយ ដែលនិយាយថា បើចង់នៅរស់មានតែបន្តធ្វើការហាក់ដូចជាគ្មានរឿងអ្វីកើតឡើង ។

បន្ទាប់មក មេធាវីការពារក្តីបានចោទសួរ សំ មេធ ពីមូលហេតុដែលគាត់មិនរត់គេចខ្លួននៅពេលមានឱកាស ។ ចម្លើយរបស់គាត់ដូចទៅនឹងកងសន្តិសុខដទៃទៀតដែរ គឺគាត់និយាយថា មិនអាចរត់គេចខ្លួនទេ ។ ការចាកចេញពីបរិវេណគុកមានការពិបាកជាខ្លាំង ហើយប្រសិនបើគេដឹងថា គាត់រត់គេចខ្លួន នោះគ្រួសាររបស់គាត់នឹងស្ថិតក្នុងគ្រោះថ្នាក់ដ៏ធំក្លាម ។ មេធាវីការពារក្តីហាក់ដូចជាបន្តវិធីសាស្ត្រដើម្បីពណ៌នាថា ឌុច ក៏ស្ថិតក្នុងកាលៈទេសៈដូចគ្នា ស្តាប់តាមបញ្ជាថ្នាក់លើ ឬ ប្រឈមមុខនឹងគ្រោះថ្នាក់ធំធេងដែលអាចនឹងបណ្តាលឲ្យបាត់បង់ជីវិត ។

### ការឆ្លើយតបរបស់ ឌុច

ឌុច មិនបានបដិសេធនឹងការពិតដែល សំ មេធ ធ្លាប់ជាកងសន្តិសុខនៅមន្ទីរស-២១នោះទេ ។ ផ្ទុយទៅវិញ គាត់បានបង្ហាញនូវការសោកស្តាយរបស់គាត់ ។ គាត់អះអាងថា គាត់មានវិប្បដិសារីចំពោះការដែលគាត់បានបញ្ចុះបញ្ចូលមនុស្សជាច្រើនឲ្យជឿតាមមនោគមន៍វិជ្ជា និងគោលនយោបាយរបស់បដិវត្តន៍ ។ គាត់ថែមទាំងបង្ហាញនូវការសោកស្តាយជាខ្លាំង ព្រោះថាគាត់មានទំនួលខុសត្រូវលើរបាយការណ៍ដែលបានប្រគល់ទៅកាន់ថ្នាក់លើ ដើម្បីចង្អុលបង្ហាញជនសង្ស័យគ្រង់ជាច្រើន ក្រោយមកអ្នកទាំងនោះត្រូវបានចាប់ខ្លួននិងសម្លាប់ ។

### ការអានសេចក្តីថ្លែងការណ៍របស់សាក្សី

អង្គជំនុំបានអនុញ្ញាតឲ្យសាក្សីមួយចំនួនអានសេចក្តីថ្លែងការណ៍របស់សាក្សី ជំនួសឲ្យការផ្តល់សក្ខីកម្មដោយផ្ទាល់ ។

សាក្សី ម៉ុក ស៊ីធីម

ម៉ុក ស៊ីធីម ជាអតីតពេទ្យនៅមន្ទីរស-២១ ។ គាត់បានព្យាបាលរបួសឲ្យអ្នកទោសជាច្រើន របួសទាំងនោះសុទ្ធតែបណ្តាលមកពីការវាយដំ និងទារុណកម្មផ្លូវកាយផ្សេងៗដូចជាដកក្រចកជាដើម ។ លើសពីនេះទៅទៀត មានអ្នកទោសមួយចំនួនប្រាប់គាត់ថា គេធ្លាប់ត្រូវឆក់ដោយចរន្តអគ្គិសនី ។ យោងតាមសេចក្តីបំភ្លឺរបស់គាត់ អ្នកសួរចម្លើយបានបញ្ជាឲ្យគាត់ព្យាបាលអ្នកទោសដើម្បីឲ្យពួកគេ បន្តការសួរចម្លើយទៀត ។

គាត់ថែមទាំងធ្លាប់ព្យាបាលអ្នកទោសប្រមាណ៣០ ទៅ៤០នាក់ដែលមានទឹកមុខស្លេកស្លាំង និងទន់ខ្សោយដោយសារត្រូវគេបូមឈាម ហើយនេះជាទម្លាប់មួយនៅក្នុងគុកទួលស្លែង ។ ប្រាក់ ខន ដែលធ្លាប់ជាអ្នកសួរចម្លើយម្នាក់នៅមន្ទីរស-២១ បានឆ្លើយបំភ្លឺពីមុនមកហើយថា ឈាមដែលបូមចេញពីលើខ្លួនអ្នកទោសត្រូវបញ្ជូនទៅកាន់មន្ទីរពេទ្យភ-១៧ និងមន្ទីរផ្សេ ។

ឌុច បដិសេធនឹងសក្ខីកម្មរបស់ មុក ស៊ីធីម ដោយនិយាយថាគាត់មិនជឿនថា មុក ស៊ីធីម ធ្លាប់ជាពេទ្យនៅក្នុងមន្ទីរស-២១ទេ ។ ទាក់ទិនទៅនឹងបញ្ហាបូមឈាម ឌុច អះអាងថាថ្នាក់លើរបស់គាត់ សុន សេន បានអានុញ្ញាតិឲ្យធ្វើដូច្នេះតាំងពីមុនពេលដែលគាត់ក្លាយជាប្រធានគុកមន្ទីរស-២១ ។ លើសពីនេះ គាត់អះអាងថា មានតែអ្នកទោសប្រហែល១០០នាក់ដែលត្រូវបូមឈាមដើម្បីបដិសេធនឹងការចោទប្រកាន់ពាក្យដែល ប្រាក់ ខន ថាមានដល់ទៅ១០០០នាក់ ។

សាក្សី តាយ តេង ហៅ ឌី តេង

តាយ តេង ជាកងសន្តិសុខនៅមន្ទីរស-២១និងជើងឯក ។ គាត់មានតួនាទីជីករណ្តៅនៅជើងឯក ។ គាត់បំភ្លឺថា ហ៊ឹម ហ៊ុយ និង កងសន្តិសុខម្នាក់ទៀតដឹកអ្នកទោសប្រហែល២០នាក់តាមរថយន្តទៅកាន់វាលពិឃាត់ ។ ការបំភ្លឺរបស់គាតស៊ីសង្វាក់គ្នានិងសក្ខីកម្មរបស់ ហ៊ឹម ហ៊ុយ ដែលបានផ្តល់ពីមុនមក ។

តាយ តេង បានបំភ្លឺយ៉ាងលម្អិតទៅលើបែបបទនៃការសម្លាប់អ្នកទោស ។ មុនពេលត្រូវគេដឹកចេញពីមន្ទីរស-២១ អ្នកទោសត្រូវចាប់ចងហើយបាំងភ្នែក ។ ពេលដែលពួកគេទៅដល់ជើងឯក អ្នកទោសទាំងអស់នឹងត្រូវនាំយកទៅឃុំនៅផ្ទះមួយចម្ងាយប្រហែល១០០ម៉ែតពីរណ្តៅកប់ខ្មោច ក្នុងខណៈពេលនោះដែរ មានអ្នកទោសពីរឬបីអ្នកនឹងត្រូវគេហៅចេញមក ។ អ្នកទោសត្រូវដាក់ឲ្យលុតជង្គង់នៅ១ម៉ែតពីរណ្តៅរួចវាយនឹងចប ។ អ្នកពិឃាតថែមទាំងយកកាំបិតមកវះពោះ ឬបំពង់-កអ្នកទោសដើម្បីធានាថា អ្នកទោសពិតជាស្លាប់បាត់មែន ។ ក្នុងរណ្តៅមួយប្រហែលជាមានសាកសព១០ ហើយនៅទីនោះមានប្រមាណជា២០ទៅ៣០រណ្តៅ ។ តាយ តេង អះអាងថាគាត់មិនដែលឃើញកុមារនៅ

វាលពិឃាតទេ។ ឌុច ទទួលស្គាល់ថា តាយ គេង ពិតជាធ្លាប់ធ្វើការនៅមន្ទីរស-២១ ហើយចម្លើយដែលរបស់គាត់សុទ្ធតែត្រឹមត្រូវ។

សាក្សី សំ សមអុល

សំ សមអុល អះអាងថាគាត់ធ្លាប់ធ្វើជាអ្នកនាំសាររបស់ក្រសួងការបរទេស។ គាត់និយាយថាមានពេលខ្លះគាត់ត្រូវបានចាត់ឲ្យបញ្ជូនសំបុត្រទៅផ្ទះ ឌុច។ ទោះបីជាគាត់មិនដែលជួបឌុចដោយផ្ទាល់ គាត់បានទុកសំបុត្រនៅ ឆេន ដែលជាអ្នកនាំសាររបស់ ឌុច។ សំ សមអុល ថែមទាំងបង្ហាញថា ឌុចបានចាត់ឲ្យ ឆេន យកឯកសារសំណេរមួយកញ្ចប់ទៅក្រសួង ដែលគាត់ប៉ាន់ស្មានថាទាំងនោះសុទ្ធតែជាចម្លើយសារភាពរបស់អ្នកទោសនៅមន្ទីរស-២១។ ឌុច ជំទាស់នឹងសក្ខីកម្មរបស់ សម សំអុល ដោយអះអាងថាគាត់មិនមែនជាអ្នកនាំសាររបស់ក្រសួងការបរទេសទេ តែគ្រាន់តែជាកងសន្តិសុខធម្មតាម្នាក់នៅមន្ទីរស-២១ប៉ុណ្ណោះ។

សំ សមអុល ថែមទាំងនិយាយថា មានមេដឹកនាំខ្មែរក្រហមមួយចំនួនមានមុខនៅក្នុងពិធីរៀបការរបស់ ឌុច។ ជាម្តងទៀត ឌុច ជំទាស់នឹងសំដីរបស់ សម សំអុល ដោយអះអាងថាខ្លួនគាត់មិនមានទំនាក់ទំនងជិតស្និទជាមួយអ្នកដឹកនាំខ្មែរក្រហមជាន់ខ្ពសណាទៀតក្រៅពី សុន សេន និង នួន ជា។ តាមសំដីរបស់គាត់ ពិធីរៀបការរបស់គាត់មិនមែនធ្វើឡើងនៅក្នុងផ្ទះគាត់ឯស្រះស្រាងនោះទេ តែគឺធ្វើឡើងនៅការិយាល័យយោធានៅភូមិភាគបស្ចិម។ គាត់ប្រកែកនឹងអំណះអំណាងថាមានវត្តមានរបស់ អៀង សារី, ខៀវ សំផន, នួន ជា, សុន សេន, និង ក្រុមខ្សែភាពយន្តចិនមួយក្រុម។ គាត់បន្តដោយរៀបរាប់ឈ្មោះភ្ញៀវដែលបានចូលរួមពិធីរៀបការរបស់គាត់ ក្នុងនោះភាគច្រើនជាបុគ្គលិកចាស់នៅមន្ទីរស-២១ជាមួយនឹងមន្ត្រីថ្នាក់ខ្ពស់មួយចំនួននៅតំបន់បស្ចិម។

សាក្សី អ៊ុក ប៊ុនសេង

អ៊ុក ប៊ុនសេង និយាយថាគាត់ធ្លាប់ជាទាហានខ្មែរក្រហមមួយរូប។ គាត់ដំបូងឡើយនៅភ្នំពេញ តែក្រោយមកត្រូវបញ្ជូនទៅដើងឯកនិងកន្លែងកសាងខ្លួនព្រៃសរ(ស-២៤)។ គាត់រៀបរាប់ថាគាត់ធ្លាប់ត្រូវបញ្ជូនទៅមន្ទីរស-២១ដើម្បី«រៀនសូត្រ»នយោបាយជាមួយ ឌុច។ គាត់ថែមទាំងអះអាងថាបានជួប ឌុច ម្តងទៀតនៅលើភ្នំក្រវាញនៅឆ្នាំ១៩៧៩ក្រោយពេលទ័ពវៀតណាមចូលមក។ គាត់អះអាងថា ឌុច បញ្ជាឲ្យគាត់ចាប់ខ្លួនមនុស្ស៦នាក់(បុរស៣នាក់និងស្ត្រី៣នាក់) ដោយសារតែធ្វើតាមសំរែកបក្សីដែលមានសម្លេងដូច «ប៉ុល ពោល»។

ឌុច បដិសេធនឹងសក្ខីកម្មរបស់ អ៊ុក ប៊ុនសេង។ ជាដំបូង គាត់និយាយថាការ«រៀនសូត្រ» ដែល អ៊ុក ប៊ុនសេង និយាយ គឺធ្វើឡើងដោយ សុន សេន ផ្ទាល់ ហើយធ្វើចំពោះតែកម្មាភិបាល

មន្ទីរស-២១ប៉ុណ្ណោះ ។ គាត់បន្តចោទប្រកាន់ថា អ៊ុក ប៊ុនសេង កុហកអំពីការចាប់ខ្លួនមនុស្ស៦នាក់ក្រោយពេលទ័ពវៀតណាមចូលមក ។ គាត់បញ្ជាក់ថា ក្រោយពីរត់ចេញពីមន្ទីរស-២១ គាត់មិនមានអំណាចដើម្បីដាក់បញ្ជាអ្វីទៀតឡើយ ។

*សក្សី មាស ប៉េងគ្រី និង តាយ តេង*

មាស ប៉េងគ្រី ធ្វើការនៅមន្ទីរស-២១ ហើយទទួលបន្ទុកក្នុងការដឹកអ្នកទោសទៅកាន់វាលពិឃាតជើងឯក ។ តាយ តេង ជាអ្នកទទួលអ្នកទោសពេលពួកគេមកដល់ ។ គាត់ថែមទាំងចូលរួមក្នុងការដឹកនិងកប់រណ្តៅដាក់សាកសពដែរ ។ គាត់ទទួលស្គាល់ថាធ្លាប់ប្រហារជីវិតអ្នកទោសម្នាក់ ឬពីរនាក់ដោយផ្ទាល់ដៃ តែគាត់បន្តថាការសម្លាប់អ្នកទោសមិនមែនជាការងារជាប្រចាំរបស់គាត់នោះទេ ។ សក្ខីកម្មអំពីដំណើរការនៃការប្រហារជីវិតអ្នកទោសនៅជើងឯកទាំងពីរនេះស៊ីសង្វាក់គ្នានឹងសក្ខីកម្មធ្លាប់មានពីមុន ហើយ ឌុច មិនបានប្រកែកដូចចំពោះសេចក្តីថ្លែងការណ៍របស់សាក្សីផ្សេងខ្លះឡើយ ។

*សាក្សី ហ៊ិន អេម ហៅ មឿង*

ហ៊ិន អេម ហៅ មឿង អាយុ៥៦ឆ្នាំ ធ្លាប់ជាកងសន្តិសុខមួយរូបនៅមន្ទីរស-២១ ។ គាត់ធ្លាប់បម្រើការងារនៅកន្លែងផ្សេងជាច្រើនមុនពេលត្រូវប្តូរមកមន្ទីរស-២១ក្នុងឆ្នាំ១៩៧៦ ។ គាត់ពន្យល់ប្រាប់ថា គាត់ធ្វើការដោយពោរពេញដោយការភ័យខ្លាចក្នុងមន្ទីរស-២១ ។ មានថ្ងៃមួយ មេឃើញគាត់មិនយកចិត្តទុកដាក់ដោយសារតែអស់កម្លាំងពេក ក៏បានព្រមានគាត់ថាបើមិនយកចិត្តក្នុងការងារនឹងត្រូវទទួលទណ្ឌកម្មយ៉ាងធ្ងន់ធ្ង ។ ក្រោយពេលមិនយូរប៉ុន្មាន គាត់ត្រូវបានចាប់ខ្លួន ចងបិតភ្នែកវាយធ្វើបាប ហើយឃុំក្នុងបន្ទប់មួយ ។ ក្រោយមក គាត់ត្រូវបានដោះលែង តែមិនត្រូវបានអនុញ្ញាតឲ្យត្រឡប់ទៅយាមក្នុងអគារឃុំឃាំងបន្តទៀតទេ ដោយប្តូរមកយាមនៅបរិវេណក្រៅគុកវិញ ។

ហ៊ិន អេម អះអាងថា គាត់បានចូលរួមក្នុងការរៀនសូត្រនយោបាយរបស់ ឌុច ដែលជាវិធីសាស្ត្រអប់រំយ៉ាងមានប្រសិទ្ធភាពមួយ ។ ការរៀននេះតម្រូវឲ្យអ្នករៀន«សម្គាល់ខ្មាំងគ្រប់រូប» ដោយមិនគិតពីទំនាក់ទំនងរវាងពួកគេ ។ តាមការបង្រៀន សូម្បីតែឪពុកម្តាយខ្លួនក៏ត្រូវជាប់សង្ស័យថាជាខ្មាំងដែរ ។ ជាក់ស្តែង មានតែមនុស្សស្អាតស្អំទេដែលអាចចាត់ទុកថាជាឪពុកម្តាយ ។

ឌុច ជំទាស់នឹងសេចក្តីបំភ្លឺទាំងមូលរបស ហ៊ិន អេម ដោយអះអាងថាជននេះមិនមែនជាកងសន្តិសុខនៅមន្ទីរស-២១ឡើយ ។